EMBASSY OF JAPAN
JAPAN INTERNATIONAL COOPERATION AGENCY (JICA)

# សេចក្តីប្រកាសព័ត៌មាន

## ពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការ ស្ពានត្សឺបាសា (Spien Tsubasa) ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុន

ភ្នំពេញ, ថ្ងៃសុក្រ ទី០៣ ខែមេសា ឆ្នាំ២០១៥

ក្រសួងសាធារណៈការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា នឹងរៀបចំពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការ **ស្ពានត្សឺបាសា (Spien Tsubasa)** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ព្រមទាំងតំណាងជាន់ខ្ពស់របស់រដ្ឋាភិបាលជប៉ុន។ ពិធីនេះនឹងត្រូវប្រារព្ធធ្វើឡើង នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៥ ចាប់ផ្តើមនៅម៉ោង៨.០០ ព្រឹក នៅការដ្ឋានសាងសង់ *(មានទីតាំងនៅប៉ែកខាងលិចនៃទន្លេមេគង្គ) ខេត្តកណ្តាល (ចម្ងាយប្រមាណជា៦០គ.ម ពីរាជធានីភ្នំពេញបើធ្វើដំណើរតាមផ្លូវជាតិលេខ១)*។

"ស្ពានត្សឺបាសា" ត្រូវបានសាងសង់ឡើងក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលជប៉ុនតាមរយៈ "គម្រោងសាងសង់ស្ពានអ្នកលឿង" ដែលត្រូវបានអនុវត្តស្របទៅតាមសំណើររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ហិរញ្ញប្បទានឥតសំណងបន្ទាន់លើការសាងសង់ស្ពានដែលមានប្រវែង២ ២១៥ ម៉ែត្រ និង ផ្លូវតភ្ជាប់ស្ពានមានប្រវែង ៣ ១០០ ម៉ែត្រ។ ទឹកប្រាក់សរុបសម្រាប់ការសាងសង់មានចំនួន ១១៩,៤ លានយ៉េន *(ចំនួនទឹកប្រាក់ក្នុងលិខិតប្តូរសារ)* ដែលប្រហាក់ប្រហែលនឹង ១២៧ លានដុល្លារសហរដ្ឋអាមេរិក *(១ដុល្លារ = ៩៤ យ៉េន ដោយយោងទៅតាមអត្រាប្តូរប្រាក់នៅឆ្នាំ២០១០ នៅពេលដែលកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងត្រូវបានចុះហត្ថលេខា)*។

ស្ពានត្សឺបាសា មិនមែនគ្រាន់តែតភ្ជាប់ផ្នែកទាំងសងខាងនៃផ្លូវជាតិលេខ១ប៉ុណ្ណោះទេ ប៉ុន្តែក៏តភ្ជាប់ប្រទេសទាំងអស់នៅក្នុងតំបន់នេះផងដែរ។ ជាងនេះទៅទៀត ស្ពាននេះនឹងធ្វើឲ្យអោយផ្លូវជាតិលេខ១ មានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការដឹកជញ្ជូននៅក្នុងតំបន់ និង ឆ្លើយតបទៅនឹងគោលនយោបាយនៃការតភ្ជាប់បណ្តាញផ្លូវហាយវេអាស៊ាន ឬ ផ្លូវហាយវេអនុតំបន់ទន្លេមេគង្គ។ យើងរំពឹងថា ស្ពាននេះនឹងចូលរួមចំណែកយ៉ាងសំខាន់ដល់ការជម្រុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយផ្លូវជាតិលេខ១ តាមរយៈការធ្វើសមាហរណកម្មផ្ទៃក្នុង និងក្នុងតំបន់ និងទូទាំងពិភពលោក។ ស្ពានត្សឺបាសា និង ផ្លូវជាតិលេខ១នេះដើរតួនាទីយ៉ាងសំខាន់ ជាផ្នែកមួយនៃការតភ្ជាប់តំបន់អាស៊ី និង អាស៊ានហាយវេលេខ១ ដែលផ្តល់ឱកាសក្នុងការបង្កើនប្រាក់ចំណូលពីការប្រកួតប្រជែងពាណិជ្ជកម្ម ទេសចរណ៍ ឧស្សាហកម្ម កសិកម្ម សុខាភិបាល សន្តិសុខ និង ឱកាសទទួលបានការងារ ជាដើម។ល។ ម្យ៉ាងវិញទៀត បន្ទាប់ពីការសាងសង់ចប់ជាស្ថាពរ ស្ពាននេះនឹងជួយកាត់បន្ថយពេលវេលាធ្វើដំណើរ និងការចំណាយទៅ

លើការដឹកជញ្ជូនបានយ៉ាងច្រើន ដែលនឹងផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាពលរដ្ឋ និង សកម្មភាពអាជីវកម្មដែលមិនមែនតែចំពោះប្រជាពលរដ្ឋដែលរស់នៅតាមផ្លូវជាតិ និង ស្ពាននោះទេ តែក៏ចំពោះប្រជាជនកម្ពុជាទាំងអស់ និងបណ្តាប្រទេសជាសមាជិកអាស៊ានផងដែរ។

លើសពីនេះទៅទៀត រដ្ឋាភិបាលជប៉ុនបាននឹងកំពុងផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់ការសាងសង់ផ្លូវជាតិលេខ១ ពីភ្នំពេញទៅអ្នកលឿងដែលការសាងសង់ចែកចេញជាបីដំណាក់កាល (ទី១ ទី២ និងទី៣) ដែលត្រូវបានបញ្ចប់រួចរាល់ហើយ នៅសល់តែដំណាក់កាលទី៤ ដែលមានប្រវែង៤គ.ម នឹងចាប់ផ្តើមធ្វើការសាងសង់ក្នុងពេលឆាប់ៗខាងមុខនេះ តាមការគ្រោងទុកអាចនឹងចាប់ផ្តើម ពីខែ មេសា ២០១៥នេះ។ រដ្ឋាភិបាលជប៉ុនក៏បានផ្តល់កម្ចីសម្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ ដើម្បីកែលម្អកំណាត់ផ្លូវជាតិលេខ៥ ពីព្រែកក្តាមដល់ប៉ោយប៉ែត និងគម្រោងអភិវឌ្ឍន៍ចំណតផែពហុបំណងកំពង់ផែក្រុងព្រះសីហនុ និង បានចាប់ផ្តើមការសិក្សាពីលទ្ធភាពនៃការសាងសង់ផ្លូវល្បឿនលឿន (Expressway) ពីភ្នំពេញទៅក្រុងបាវិត។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងស្ថានទូតជប៉ុនប្រចាំកម្ពុជា:*
Mr. MITORI Naoki *ឬ* Mr. CHIBA Taizo *តាមរយៈទូរស័ព្ទលេខ* 023 217 161

(ចប់ទំព័រ)